# ប្រទេសកម្ពុជាក្រោមការពិនិត្យឡើងវិញនៃអនុសញ្ញា ស៊ី-ដ

គណៈកម្មាធិការស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើសប្រឆាំងនឹងនារីភេទ ("គណៈកម្មាធិការស៊ី-ដ") គឺជាក្រុមដែលមានសមាសភាពអ្នកជំនាញឯករាជ្យទៅលើសិទ្ធិស្ត្រីចំនួន ២៣ រូប ដែលធ្វើការតាមដានទៅលើការអនុវត្តអនុសញ្ញា ស៊ី -ដ របស់រដ្ឋភាគីដែលបានផ្តល់សច្ចាប័ន។



៤ឆ្នាំ

រដ្ឋភាគីមានកាតព្វកិច្ចក្នុងការដាក់របាយការណ៍ជាទៀងទាត់ជូនគណៈកម្មាធិការជារៀងរាល់ ៤ឆ្នាំម្តង។

របាយការណ៍តាមការ កំណត់លើកទី១ ទី២ និងទី៣ គឺនៅខែមករា ឆ្នាំ២០០៦

របាយការណ៍តាមការ កំណត់លើកទី៤ និងទី៥ គឺនៅខែតុលា ឆ្នាំ២០១៣

របាយការណ៍តាមការ កំណត់លើកទី៦ គឺនៅខែតុលា ឆ្នាំ២០១៩

គណៈកម្មាធិការស៊ី-ដ បានពិនិត្យឡើងវិញទៅលើប្រទេសកម្ពុជានៅក្នុងសម័យប្រជុំលើកទី ៧៤ របស់ខ្លួនទៅលើការអនុវត្តសិទ្ធិស្ត្រីដូចដែលមានចែងនៅក្នុងអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ (អនុសញ្ញា ស៊ី-ដ)។

## ការចូលរួមរបស់អង្គការសង្គមស៊ីវិល

ដើម្បីទទួលបានព័ត៌មានត្រឹមត្រូវបំផុត គណៈកម្មាធិការ ស៊ី-ដ ស្វាគមន៍អង្គការសង្គមស៊ីវិលជាតិ និងអន្តរជាតិដើម្បីផ្តល់ព័ត៌មានជាក់លាក់របស់ប្រទេសខ្លួន។

## តើអង្គការសង្គមស៊ីវិលអាចធ្វើអ្វីបានខ្លះ?

ដាក់របាយការណ៍ជាលាយលក្ខណ៍អក្សរមុនកិច្ចប្រជុំមុនវគ្គទៅលើអនុសញ្ញា ស៊ី-ដ ឬក៏មុនកិច្ចប្រជុំគណៈកម្មាធិការ។

ចូលរួមកិច្ចប្រជុំក្នុងក្រុមការងារមុនវគ្គ និងកិច្ចប្រជុំរបស់គណៈកម្មាធិការ។ នៅវគ្គទាំងនេះ មានការកំណត់ពេលវេលាសម្រាប់សង្គមស៊ីវិលក្នុងការផ្តល់ព័ត៌មានដោយផ្ទាល់មាត់។

សង្គមស៊ីវិលអាចរៀបចំជាព្រឹត្តិការណ៍ផ្សេងៗដាច់ដោយឡែកសម្រាប់សមាជិកគណៈកម្មាធិការក្នុងអំឡុងពេលសម័យប្រជុំ។

បន្ទាប់ពីការពិនិត្យឡើងវិញ សង្គមស៊ីវិលអាចជួយ និងសហការជាមួយអ្នកដែលពាក់ព័ន្ធទាំងអស់ក្នុងការអនុវត្តនូវអនុសាសន៍ ព្រមទាំងចូលរួមឃ្លាំមើល និងធ្វើរបាយការណ៍ពីការអនុវត្តអនុសាសន៍ទាំងនោះ។

## ហេតុអ្វីបានជាអង្គការសង្គមស៊ីវិលគួរតែចូលរួម?

អង្គការសង្គមស៊ីវិលអាចមានឥទ្ធិពលលើលទ្ធផលនៃការពិនិត្យឡើងវិញ។

អង្គការសង្គមស៊ីវិលអាចផ្តល់ការវាយតម្លៃដោយឯករាជ្យពីស្ថានភាពសិទ្ធិមនុស្សដែលអាចប្រៀបធៀបទៅនឹងរបាយការណ៍ថ្នាក់ជាតិបាន។

អង្គការសង្គមស៊ីវិលអាចដើរតួនាទីយ៉ាងសំខាន់ក្នុងការឃ្លាំមើល និងគាំទ្រដល់ការអនុវត្តអនុសាសន៍ ដូច្នេះអាចបង្កើននូវផលជះនៃអនុសញ្ញា ស៊ី-ដ និងអាចលើកកម្ពស់នូវការលុបបំបាត់ការរើសអើងប្រឆាំងនឹងនារីភេទ។

## របាយការណ៍អង្គការសង្គមស៊ីវិលបានដាក់ជូនក្រុមការងារមុនពេលការពិនិត្យឡើងវិញ

- អង្គការសង្គមស៊ីវិលបានដាក់ជូនរបាយការណ៍ពាក់ព័ន្ធនឹងកម្ពុជាទៅកាន់ក្រុមការងារមុនវគ្គ។ របាយការណ៍ទាំងនេះអាចចូលមើលបានតាមរយៈ៖ https://bit.ly/2Njsy6k
- របាយការណ៍ទាំងនោះមានបញ្ជីបញ្ហា ព្រមទាំងសំណួរដែលបានស្នើឡើងសម្រាប់ដំណើរការពិនិត្យឡើងវិញនៃប្រទេសកម្ពុជា។
- មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (ម.ស.ម.ក) សមាគមការពារសិទ្ធិមនុស្សនិងអភិវឌ្ឍន៍នៅកម្ពុជា (អាដហុក) អង្គការគោលដៅយុត្តិធម៌ (Destination Justice) អង្គការក្លាហាន និងអង្គការនារីដើម្បីសន្តិភាព បានដាក់របាយការណ៍រួមមួយស្តីពីការទទួលបានយុត្តិធម៌។ របាយការណ៍នេះអាចរកបានតាមរយៈ៖ https://bit.ly/2pXDr5J

ឧបត្ថម្ភដោយ

EUROPEAN UNION · DCA actalliance · VOICES for GENDER EQUALITY

ផលិតដោយ

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា Cambodian Center for Human Rights

@CCHRCambodia @CCHRCambodia @EU.Cambodia

BY NC SA

ខែមិថុនា ឆ្នាំ២០២០